

# ផ្ទះរបស់ប៊ូគី

Let's Read

The Asia Foundation



ម៉េវ! ម៉េវ! ប៉ូគី កំពុងរកកន្លែងដេក។ ប្រអប់ក្រដាសនោះមើលទៅទំនងដេកស្រួលហើយ។ តើ ប៉ូគី អាចដេកនៅទីនោះបានទេ?



អុះ! ប្រអប់នោះពេញហើយ។ ”តើឯងកំពុងតែរកអ្វី? នៅទីនេះគ្មានកន្លែងទំនេរទេ។” ឆ្មាមួយនិយាយ។



ពេលនេះ ប៉ូគី ត្រូវស្វែងរកកន្លែងផ្សេងទៀត។ នៅក្បែរនោះ មានធុងសំរាមមួយ។ "ម៉េវ! ម៉េវ! តើខ្ញុំអាចដេកទីនេះបានទេ?"



”នៅទីនេះគ្មានកន្លែងសម្រាប់ឯងទេ។ ទីនេះពេញហើយ” ឆ្មានៅក្នុងធុងសំរាមនោះនិយាយ។
តើឥឡូវ ប៉ូគី គួរទៅទីណា?



ប៉ូគី ក៏ដើរចេញទៅ។ ខ្យល់បក់កាន់តែខ្លាំង។ មេឃកាន់តែងងឹតទៅៗ។ ប៉ូគី មានអារម្មណ៍ថារងាណាស់។ វាមិនអាចដេកបានទេ ដោយសារសំឡេងចរាចរណ៍រំខាន។



អូ! មេឃទំនងជាភ្លៀងខ្លាំងហើយ។ ប៉ូគី ត្រូវតែរកកន្លែងដេក!



ទីបំផុត ប៉ូគី រកឃើញផ្ទះមួយនៅក្បែរនោះ។



ប៉ូគី គិតថា វាសំណាងណាស់ដែលរកឃើញផ្ទះនេះ។ ទីនេះមានបន្ទប់តូចមួយខាងក្រោមដំបូលផ្ទះដែលវាអាចស្នាក់នៅបាន។ ប៉ុន្តែវានៅតែមានអារម្មណ៍ថារងា។



រំពេចនោះ ភ្នែករបស់ ប៉ូគី ស្រវាំងមើលអ្វីមិនឃើញដោយសារ
ពន្លឺសម្លួយចាំងឆ្វាច ហើយក៏...
ផាំង!!



ព្យុះមានផ្គរ និងរន្ទះផង។ ប៉ូគី ស្លុតយ៉ាងខ្លាំង។ នៅខាងក្រោម
នោះ ភ្លើងកំពុងឆេះរាលដាលពេញដី រួមទាំងប្រអប់ក្រដាស និង
ធុងសំរាមផងដែរ!



"ម៉េវ! ម៉េវ! ទាំងអស់គ្នា មកទីនេះមក!" ប៉ូគី ស្រែកហៅមិត្ត
ទាំងអស់របស់វា។



ឆ្មាទាំងអស់ ក៏ឡើងទៅកន្លែងដែល ប៉ូគី នៅ។



ឥឡូវពួកវានៅជុំគ្នាទីនេះ។



ឥឡូវតើ ប៉ូគី គួរដេកកន្លែងណា? កន្លែងនេះ ចង្អៀតណាស់។



ខ្ញុំគិតថា យើងអាចគេងជុំគ្នាបែបនេះបាន។

 ប៊ូគី មិនប្រកាន់នឹងគេងប្រជ្រៀតគ្នាឡើយ។ វាថែមទាំងធ្វើឱ្យគេមានអារម្មណ៍កក់ក្តៅផង។

អេស ...ប៊ូគីគេងលក់យ៉ាងស្កប់ស្កល់។

The Asia Foundation
Improving Lives, Expanding Opportunities

litara
Foundation

រក្សាសិទ្ធិដោយ មូលនិធិអាស៊ី ឆ្នាំ២០១៩
សៀវភៅនេះត្រូវបានផលិតឡើងតាមរយៈសិក្ខាសាលាស្តីពីការផលិតសៀវភៅ ក្រោមកិច្ចសហការរវាងមូលនិធិ លីតារ៉ា និងមូលនិធិអាស៊ី។ សិក្ខាសាលា និងការអភិវឌ្ឍជំនាញ រួមទាំងការកែសម្រួល និងរចនាសៀវភៅនេះ ត្រូវបានធ្វើឡើងដោយមូលនិធិ លីតារ៉ា។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Poki Golek Omah (Poki's Home)*, Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/
Contributing translators: Somey Chheang and Chou Chinith